**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN No : 1118
Date: 12-09-11 Time: 10:20
For : GMAC


**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :** ១៦៨ **ក.ប** / ល.ន.ល


រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ
## និង
## ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

យោងតាមប្រកាសរបស់ក្រសួងលេខ ១៩៦ កប/ប្រក. ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១០ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល យោងតាមលិខិតលេខ ៣២០/១១ គ.ជ.ប ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ខែ កញ្ញា ដល់ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០១១ និងយោងតាមសំណូមពរចាំបាច់របស់កម្មករនិយោជិត និងនិយោជក។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ មេត្តាអនុញ្ញាតឲ្យកម្មករនិយោជិតបានឈប់សម្រាកតាមកាលបរិច្ឆេទ ដូចខាងក្រោម ៖

**១- ការអនុញ្ញាតឲ្យកម្មករនិយោជិតបានឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ**

ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ សូមលោក លោកស្រី ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវអនុញ្ញាតឲ្យកម្មករនិយោជិតទាំងអស់របស់ខ្លួនឈប់សម្រាកដោយមានប្រាក់ឈ្នួល ក្នុងកំឡុងពេលបីថ្ងៃគឺ ថ្ងៃទី ២៦ - ២៧ និងថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១១។

**២- ការអនុញ្ញាតឲ្យកម្មករនិយោជិតបានទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

ក-ថ្ងៃ ព្រហស្បតិ៍ ទី ២៩ ខែ កញ្ញា ឆ្នាំ២០១១ សម្រាប់កម្មករនិយោជិតធ្វើការនៅរាជធានីភ្នំពេញ - ខេត្ត ហើយត្រូវទៅពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត នៅក្នុងរាជធានីភ្នំពេញ - ខេត្តនោះផ្ទាល់។

ខ-ថ្ងៃ ព្រហស្បតិ៍ ទី ២៩ និងថ្ងៃ សុក្រ ទី ៣០ ខែ កញ្ញា ឆ្នាំ២០១១ សម្រាប់កម្មករនិយោជិតធ្វើការនៅរាជធានីភ្នំពេញ ត្រូវចេញពីរាជធានីភ្នំពេញទៅ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប និងខេត្តព្រះសីហនុ។




*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤ ៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

គ-ថ្ងៃ ព្រហស្បតិ៍ទី ២៩, ថ្ងៃ សុក្រ ទី ៣០ ខែ កញ្ញា និងថ្ងៃ សៅរ៍ ទី០១ ខែ តុលា ឆ្នាំ២០១១ សម្រាប់កម្មករនិយោជិតធ្វើការនៅរាជធានីភ្នំពេញ ទៅខេត្តផ្សេងៗក្រៅពីខេត្ត ដែលចែងក្នុងចំណុចទីខ ខាងលើ ។

ឃ-ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងនៅក្នុងខេត្តដទៃទៀត ក្រៅពីរាជធានីភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិតតាមកំណត់ដូចចែងក្នុងចំណុចទីខ និងទីគ ខាងលើដែរ ដោយយកខេត្តនីមួយៗ ធ្វើជាមូលដ្ឋានដើម ដូចគ្នានឹងរាជធានីភ្នំពេញដែរ ។

**៣- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមគូសបញ្ជាក់ប្រការមួយចំនួនដែលត្រូវយកចិត្តទុកដាក់គឺ ៖**

ក- រាល់ការអនុញ្ញាតច្បាប់ជូនកម្មករនិយោជិត ដូចមានចែងខាងលើនេះ និយោជកត្រូវរក្សាទុកប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ជូនកម្មករនិយោជិតនៅដដែល ។

ខ- ចំពោះកម្មករនិយោជិត ដែលអវត្តមានហួសពីច្បាប់អនុញ្ញាត ដូចមានចែងខាងលើនេះ ត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន ។

គ- ខិតខំរៀបចំបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតឲ្យបានមុនថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ។

ឃ- បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទាន់ពេលទេ សូមអនុញ្ញាតឲ្យកម្មករនិយោជិតទទួលប្រាក់ឈ្នួលមួយភាគជាបុរេប្រទានមុនពេលឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ។

សេចក្តីជូនដំណឹងលេខ ១៦៧ ក.ប/សជណ. ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១១ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ត្រូវចាត់ទុកជានិរាករណ៍ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ព្រមទាំងកម្មករនិយោជិតទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- កាលប្បវត្តិ - ឯកសារ